**Declassified to Public**
**06 September 2012**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 07 / 2008
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

សំណុំរឿងព្រហ្មទណ្ឌ
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**
**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 001/18-07-2007-ECCC-OCIJ**

# ដីកាសម្រេចលើពាក្យសុំពន្យារពេល
# Ordonnance sur demande de prolongation de délai
# Order on request for extension of time

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 18 / 07 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

យើង យូ ប៊ុនឡេង និង Marcel LEMONDE (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤

បានឃើញវិធាន ៣៩.៤ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច**

ត្រូវបានដាក់ឱ្យក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និង ការរំលោភបំពានធ្ងន់ធ្ងរលើសន្ធិសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ៦ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះ វិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤។

បានឃើញដីកាសម្រេចរបស់យើងស្តីអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០០៨ ជាពិសេសនៅក្នុងចំណុចទីពីរនៃសេចក្តីសម្រេចដែលមានខ្លឹម សារថា៖ ភាគីនានាត្រូវដាក់



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C.

ជូនទៅផ្នែកគ្រប់គ្រងតុលាការ ឲ្យបានមុនថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៨ នូវបញ្ជីឯកសារដែលខ្លួនចាត់ទុកជាបញ្ហាអាទិភាពទាមទារឲ្យមានការបកប្រែ រួមទាំងសំណើនានាឲ្យ កែប្រែសំណើសុំបកប្រែពីមុនដែលមិនទាន់បានបញ្ចប់។

បានឃើញសំណើរបស់មេធាវីការពារក្តីរបស់ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ដែលបានដាក់និងជូនដំណឹងនៅថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០០៨ សុំឲ្យពេលវេលាបន្ថែមសម្រាប់ការបញ្ជូននូវបញ្ជីឯកសារដែលត្រូវបកប្រែ និងបានឃើញការបញ្ជាក់អំពីហេតុផលនៃសំណើនោះ។

ហេតុដូច្នេះ សម្រេចថា មេធាវីការពារក្តីរបស់ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ត្រូវបញ្ជូនបញ្ជីឯកសារនោះមកឲ្យយើងឲ្យបានមុនថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៨។

ភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០០៨

**សហចៅក្រមស៊ើបអង្កេត**

**Co- Investigating Judges**

**Co-juges d'instruction**

**Lemonde MARCEL** **យូ ប៊ុនឡេង**



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.